# ព្រះរាជក្រម

នស/រកម/០៦១៤/០១៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើលិខិតសន្យាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស៊ីធីលុម អេសអេ សម្រាប់គម្រោងវិនិយោគសាងសង់ ផ្ទេរ និងប្រតិបត្តិការអគ្គិសនីហេដ្ឋារចនាសម្ព័ន្ធសេវាបំភ្លឺសាធារណៈនៅរាជធានីភ្នំពេញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើលិខិតសន្យាទូទាត់របស់រាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុនស៊ីធីលុម អេសអេ សម្រាប់ គម្រោងវិនិយោគសាងសង់ ផ្ទេរ និងប្រតិបត្តិការ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសេវាបំភ្លឺ សាធារណៈនៅរាជធានីភ្នំពេញ

**មាត្រា ១.-**

អនុម័តយល់ព្រមលើលិខិតសន្យាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុនស៊ីធីលុម អេសអេ ដែលជាលិខិតុបករណ៍សម្រាប់គម្រោងវិនិយោគសាងសង់ ផ្ទេរ និងប្រតិបត្តិការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសេវាបំភ្លឺសាធារណៈនៅរាជធានីភ្នំពេញ ដែលបានចុះហត្ថលេខា នៅរាជធានីភ្នំពេញ នាថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ ។ លិខិតសន្យានេះ មានអត្ថបទទាំងស្រុង ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តលិខិតសន្យាទូទាត់នេះ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០៦១៤.០៥៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**អូន ព័ន្ធមុនីរ័ត្ន**

លេខៈ ៧៦៥ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ:.០០៦.........សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២

**លិខិតសន្យារបស់រាជរដ្ឋាភិបាលលើការទូទាត់**

**ជូនចំពោះ ៖ លោក** Michel TESCONI
**ក្រុមហ៊ុន ស៊ីធីលុម អេសអេ** (Citelum S.A)
**អាសយដ្ឋាន ៖** 37, Rue de Lyon, 75012 Paris, France

**យោង ៖**

(ក) សិទ្ធិប្រទានលេខ ១៣០ សប្រទ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១២ ដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (លិខិតសិទ្ធិ ប្រទាន ក្នុងឧបសម្ព័ន្ធ១)។

(ខ) កិច្ចសន្យាសាងសង់ ផ្ទេរ និងប្រតិបត្តិការ ( BTOC ) ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០១២ ដែលបានចុះហត្ថលេខា រវាងសាលារាជធានីភ្នំពេញ ( សាលារាជធានី ) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( កសហវ ) ជាសហហត្ថលេខី និងក្រុមហ៊ុនស៊ីតេលូម (**ក្រុមហ៊ុន**) ស្តីពីគម្រោងសាងសង់ ទំនើប ផ្ទេរ និងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធ និង សេវាបំភ្លឺសាធារណៈ (**គម្រោង**)។

(គ) ការយល់ព្រមជាក់លាក់លើសេចក្តីថែងនៃ BTOC ដោយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ដូចដែលបានធានាដោយហត្ថលេខារបស់ខ្លួនក្នុង BTOC។

(ឃ) លក្ខខណ្ឌបង្អង់សុពលភាពនៃកាលបរិច្ឆេទចូលជាធរមាននៃ BTOC ដូចមានចែងក្នុងខ ១.៤.១ (គ) នៃកិច្ចសន្យាដែលថាសាលារាជធានីភ្នំពេញត្រូវបើកគណនីទូទាត់ដោយឡែកមួយ សម្រាប់បើកផ្តល់ហិរញ្ញប្បទានឲ្យគម្រោង (**គណនីទូទាត់**)។

(ង) លក្ខខណ្ឌបង្អង់សុពលភាពនៃកាលបរិច្ឆេទចូលជាធរមាននៃ BTOC ដូចមានចែងក្នុងខ ១.៤.១ (ក) នៃ កិច្ចសន្យាដែលថាកសហវយល់ព្រមចេញលិខិតជូនក្រុមហ៊ុនដែលតាមរយៈលិខិតនោះ កសហវសូម សន្យាថាក្នុងអំឡុងពេលនៃអាណត្តិទាំងមូលនៃ BTOCថា៖

(i) បន្ទាប់ពីសាលារាជធានីភ្នំពេញបានស្នើសុំជាលាយលក្ខណ៍អក្សរលើកដំបូង កសហវនឹងផ្ទេរទឹកប្រាក់ឱ្យបានគ្រប់គ្រាន់ចេញពីរតនាគារជាតិចូលទៅក្នុងគណនីទូទាត់ជារៀងរាល់ត្រីមាសដើម្បីរក្សាទុកជាប្រាក់បញ្ញើបុរេប្រទានសម្រាប់ការទូទាត់ថ្មីបន្តទៀតដែលត្រូវបានតម្រូវ ចំពោះសាលារាជធានីក្នុងអំឡុងត្រីមាសពាក់ព័ន្ធ នាពេលអនុវត្ត BTOC និង

(ii) កសហវធានាឱ្យបានថា សមតុល្យទឹកប្រាក់ជាប្រចាំ មិនត្រូវតិចជាងប្រាំបួនរយពាន់ (៩០០.០០០) ដុល្លារអាមេរិក ដែលត្រូវបានរក្សាទុកក្នុងគណនីទូទាត់ នាគ្រប់ពេលវេលាទាំងអស់។



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**ដូច្នេះ យើងខ្ញុំសូមសន្យាថា៖**

១. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងអនុញ្ញាតឲ្យសាលារាជធានីបើកគណនីទូទាត់ជាប្រាក់ដុល្លារអាមេរិក នៅធនាគារប្រតិស្រុតិណាមួយដែលមានទីតាំងនៅព្រះរាជាណាចក្រកម្ពុជា។

២. គណនីទូទាត់នេះមានប្រភពមកពីមួយចំណែកនៃចំណូលដែលប្រមូលបានពីអាករបំភ្លឺសាធារណៈក្នុង ដែនសមត្ថកិច្ចរបស់រាជធានីភ្នំពេញ ឬពីចំណូលផ្សេងទៀតនៃថវិកាសាលារាជធានី ។

៣. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងផ្តត់ផ្តង់ឲ្យបានថាអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋាន ពន្ធដារ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន រតនាគាររាជធានីភ្នំពេញ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សាលា-រាជធានី និងនាយកដ្ឋានពាក់ព័ន្ធដទៃទៀតដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងអនុវត្ត ការសន្យានានា ដូចមានចែងក្នុងកថាខណ្ឌ ១ និង កថាខណ្ឌ ២ ខាងលើប្រកបដោយប្រសិទ្ធភាព។

៤. កសហវនឹងទទួលស្គាល់ ឬផ្តល់ការធានាផ្លូវច្បាប់ដល់បំណុលណាមួយ ដែលជាបន្ទុករបស់សាលារាជ ធានី ចំពោះក្រុមហ៊ុនក្រោមក្របខណ្ឌនៃ BTOC។

៥. នៅក្នុងអំឡុងពេលនៃអាណត្តិទាំងមូលនៃ BTOC ក្រោយពីបានទទួលលិខិតជូនដំណឹងពីសាលារាជធានី ដែលបញ្ជាក់ពីចំនួនប្រាក់ជាដុល្លារអាមេរិកពាក់ព័ន្ធនៃប្រាក់បញ្ញើបុរេប្រទានដែលចាំបាច់ ត្រូវផ្ទេរចូល គណនីទូទាត់ សម្រាប់ការទូទាត់បន្តបន្ទាប់ដែលត្រូវបានតំរូវដោយសាលារាជធានី នៅក្នុងអំឡុងរៀង រាល់ត្រីមាសនៃការអនុវត្ត BTOC នោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងប្តូរចំនួន សាច់ប្រាក់ទាំងនេះ ទៅជាដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់ដែលកំពុងអនុវត្តនាថ្ងៃនៃប្រតិបត្តិការប្តូរប្រាក់នេះ បន្ទាប់មក ផ្ទេរចំនួន សាច់ប្រាក់ដែលបានប្តូរនេះចូលទៅក្នុងគណនី ទូទាត់ដើម្បីធានាថា សមតុល្យសាច់ប្រាក់ជា ប្រចាំមិនតិច ជាងប្រាំបួនរយពាន់ (៩០០.០០០) ដុល្លារអាមេរិក ដែលត្រូវបានរក្សាទុកក្នុងគណនីទូទាត់ នាគ្រប់ពេលវេលាទាំងអស់។

៦. កសហវ ផ្តល់កិច្ចប្រឹងប្រែង និងសហការដ៏ប្រសើររបស់ខ្លួន ដើម្បីធានាថាសាលារាជធានី នឹងអនុវត្ត កាតព្វកិច្ចទូទាត់ របស់ខ្លួនជូនក្រុមហ៊ុន ក្រោមក្របខណ្ឌនៃ BTOC។

៧. ដើម្បីចៀសវាងក្តីមន្ទិល ការសន្យាដែលបានលើកឡើងនៅទីនេះមិនមែនជាការសន្យាជាប់លាប់តាម បែបធានានោះឡើយ។ ដូច្នេះហើយការសន្យាដែលពាក់ព័ន្ធមិនត្រូវពង្រីកទៅដល់ សមតុល្យទឹកប្រាក់ ដែលត្រូវបង់ឲ្យក្រុមហ៊ុននាពេលណាមួយ ដោយសាលារាជធានីក្រោមក្របខណ្ឌ BTOC ឡើយហើយ ការសន្យានេះ ក៏មិនត្រូវបានចាត់ទុកដូចជាកិច្ចព្រមព្រៀងមួយសម្រាប់ជំនួសដែលថា កសហវ ក្លាយ ទៅជាកូនបំណុលរបស់ក្រុមហ៊ុន ជំនួសឲ្យសាលារាជធានី ក្នុងករណីដែលសាលារាជធានីមានកំហុស ក្រោមក្របខណ្ឌ BTOC បានឡើយ។

៨. កសហវ ទទួលស្គាល់ថាការមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដែលអាចកើតមានឡើងក្រោមក្របខណ្ឌនៃ លិខិតសន្យានេះ ក្នុងជ្រុងណាមួយអាចជាព្រឹត្តិការណ៍មិនអាចគ្រោងបានដូចដែលបានកំណត់ក្នុងខ ១.៨.២ នៃ BTOC ហើយក្នុងន័យនេះ អាស្រ័យដោយចំនួនរយៈពេលអូសបន្លាយនៃការមិនបានអនុវត្តអាចនាំ ទៅដល់ការខាននៃសេដ្ឋកិច្ចទូទៅនៃកិច្ចសន្យា។

៩. កសហវ សូមបង្ហាញ និងអះអាងនៅថ្ងៃនេះថា៖

(ក) លិខិតសន្យានេះជាកាតព្វកិច្ចស្របច្បាប់ មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណង ផ្លូវច្បាប់របស់កសហវ ដោយអនុលោមតាមអាណត្តិនៃលិខិតសន្យានេះ។

(ខ) រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងការយល់ព្រមដែលតម្រូវឲ្យមានត្រូវបានទទួលរួច ហើយក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខាការប្រគល់ និងការប្រតិបត្តិលិខិតសន្យានេះ។

(គ) ការចុះហត្ថលេខា ការប្រគល់ និងការអនុវត្តដោយកសហវ តាមលិខិតសន្យានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតសន្យានេះ ជាសកម្មភាពដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ។

១០. លិខិតសន្យានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទចូលជាធរមាន (Effective Date) រហូតដល់បញ្ចប់អាណត្តិនៃ BTOC និងត្រូវបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ណាមួយ ដែលសាលារាជធានីនៅជំពាក់ក្រុមហ៊ុនទាក់ទងនឹងអាណត្តិនោះ ឬនៅពុំទាន់ទូទាត់។

១១. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលត្រូវហៅកាត់រួមគ្នាថា " លិខិតជូនដំណឹង ដែលត្រូវផ្តល់ ឬធ្វើឡើងស្របតាមលិខិតសន្យានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូនទៅបុគ្គល និងអាសយដ្ឋានដូចមានបញ្ជាក់ខាងក្រោមដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមប្រៃសណីយ៍។ រាល់លិខិតជូនដំណឹងត្រូវបានចាត់ទុកថាបានប្រគល់៖

(ក) ពេលបានប្រគល់ផ្ទាល់ដៃ, ឬ

(ខ) នៅពេលប្រគល់ដោយមានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួលដោយអ្នកផ្ញើឯកសារអន្តរជាតិដែលមានការទទួលស្គាល់ បញ្ជូនទៅភាគីទទួល ទៅកាន់អាសយដ្ឋាន ដូចខាងក្រោម (ឬក៏អាសយដ្ឋានដទៃទៀតដែលភាគីទទួលនោះអាចបញ្ជាក់តាមរយៈលិខិតជូនដំណឹង ឲ្យទៅភាគីប្រគល់លិខិត តាមអាសយដ្ឋាន ឬលេខទូរសារ ដូចចែងខាងក្រោម)៖

សម្រាប់ កសហវ ៖

ជូនចំពោះ៖ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អាសយដ្ឋាន៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ផ្លូវលេខ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ទូរសារលេខ៖ ៨៥៥ ២៣ ៤២៧ ៧៩៨

សម្រាប់ក្រុមហ៊ុន៖

អាសយដ្ឋាន៖ ស៊ីធីលុម (កាំបូដ) ខូ អិលធីឌី (c/o CITELUM (CAMBODGE) Co. Ltd)
លេខ១, ផ្លូវ ១៥០, សង្កាត់វាលវង់, ខណ្ឌ ៧ មករា, រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ទូរសារលេខ៖ ៨៥៥ ១២ ២៣ ០៨ ០៨

ជូនចំពោះ ៖ លោក អៀប អេងហុង (Mr. EAP Eng Hong)

ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីណាមួយអាចជូនដំណឹងឲ្យភាគីមួយទៀត។

១២. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធនឹង លិខិតសន្យានេះ ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ បន្ទាប់ភាគីមួយបាន ទទួលសេចក្តីជូន ដំណឹង ពីភាគីមួយទៀតស្តីពីការកើតឡើងនៃវិវាទ កសហវ និងក្រុមហ៊ុន ត្រូវដោះស្រាយ វិវាទនោះតាមរយៈការពិភាក្សាជាមិត្តភាព។ ប្រសិនបើមិនអាចដោះស្រាយបានតាមរយៈការ ពិភាក្សាជាមិត្តភាពទេ ត្រូវដាក់វិវាទនោះទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាននៃមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ។

១៣. ប្រសិនបើបញ្ញត្តិណាមួយ ឬច្រើនដែលមានក្នុងលិខិតសន្យានេះ ត្រូវបានរកឃើញថាគ្មានសុពលភាព ខុសច្បាប់ ឬគ្មានតម្លៃតាមផ្លូវច្បាប់ បញ្ញត្តិទាំងនោះត្រូវរក្សាតម្លៃដែលអនុញ្ញាតដោយច្បាប់ ហើយភាពគ្មានសុពលភាព ភាពខុសច្បាប់ ឬភាពគ្មានតម្លៃតាមផ្លូវច្បាប់នោះ ពុំមានឥទ្ធិពលដល់ សុពលភាពនៃបញ្ញត្តិផ្សេងទៀតនៃលិខិតសន្យានេះឡើយ។ តាមការ ឯកភាពគ្នាទៅវិញទៅមក គ្មានការទូទាត់កាត់កង ការប្តឹងទាមទារទៅវិញទៅមក ការបន្ធូរ បន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយ ដែល កសហវ មានឬអាចមានចំពោះក្រុមហ៊ុន ត្រូវតែ មានសម្រាប់កសហវចំពោះក្រុមហ៊ុន ដែលទាក់ទិនទៅនឹងកាតព្វកិច្ចណាមួយរបស់កសហវ ចំពោះ ក្រុមហ៊ុន ក្រោមលិខិតសន្យានេះឡើយ។

១៤. ពាក្យសរសេរជាអក្សរធំដែលបានប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតសន្យានេះ ត្រូវមាន ន័យដូចបានកំណត់ក្នុង BTOC តាមដែលអាចអនុវត្តបាន។

១៥. លិខិតសន្យានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្តទៅបាន បន្ទាប់ពីទទួលបាន សច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

សូមលោកមេត្តាទទួលនូវការរាប់អាន ពីខ្ញុំ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- -ក្រសួងមហាផ្ទៃ
- -ក្រសួងសាធារណការ និងដឹកជញ្ជូន
- -ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- -សាលារាជធានីភ្នំពេញ
- -ឯកសារ-កាលប្បវត្តិ